ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើររបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានរៀបចំកែសំរួលនាយកដ្ឋាននគរបាលរដ្ឋបាល និងនាយកដ្ឋានសន្តិសុខសង្គមទៅជានាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន និងនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គិភ័យ ដែលស្ថិតនៅចំណុះនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ។

ការរៀបចំកែសំរួលនាយកដ្ឋានទាំងពីរនេះ ក្នុងទិសដៅពង្រឹងតួនាទី ភារកិច្ច និងបង្កើនសមត្ថភាពលើការងារដឹកនាំគ្រប់គ្រងកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ការចុះបញ្ជីស្ថិតិប្រជាពលរដ្ឋ ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការផ្តល់លិខិតឆ្លងដែនជូនប្រជាពលរដ្ឋ ការ

www.pheakdeylaw.com

ចុះបញ្ជីមុខរបបពិសេស គ្រប់គ្រងអាវុធ ជាតិផ្ទុះ និងការងារបង្ការ ពន្លត់អគ្គីភ័យអោយកាន់តែមានប្រសិទ្ធភាពថែមទៀត ។

ជំពូកទី២

អំពីរចនាសម្ព័ន្ធគ្រប់គ្រង

មាត្រា២.-

- នាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែនដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

- នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គីភ័យ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

មាត្រា៣.-

នាយកដ្ឋាននគរបាលស្ថិតិនិងលិខិតឆ្លងដែន និងនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គីភ័យ មាន ការិយាល័យមួយចំនួន ចំណុះ ។

ការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងបរិមាណមន្ត្រីរបស់ការិយាល័យចំណុះ នៃនាយកដ្ឋានទាំងពីរខាងលើកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ជំពូកទី៣

អំពីសមត្ថកិច្ច និងភារកិច្ច

មាត្រា៤.-

នាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន មានសមត្ថកិច្ច និងភារកិច្ចដូចខាងក្រោម :

១- ពិចារណាផ្តើមយោបល់អំពីគោលការណ៍ ជូនថ្នាក់ដឹកនាំក្រសួង អគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីដាក់ចេញនូវផែនការ វិធានការជាក់ស្តែងសំដៅលើកកំពស់ប្រសិទ្ធភាពការងារ :

- គ្រប់គ្រងការចុះបញ្ជីស្ថិតិប្រជាពលរដ្ឋ
- គ្រប់គ្រងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ
- ពិនិត្យផ្តល់ និងគ្រប់គ្រងលិខិតឆ្លងដែនជូនប្រជាពលរដ្ឋ
- គ្រប់គ្រងការចុះបញ្ជីមុខរបរពិសេស

២- សហការស្រាវជ្រាវរកមនុស្សបាត់ខ្លួន និងគ្រួសារដែលបាត់ដំណឹង ។

៣- ផ្តើមគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួង អគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីដាក់ចេញនូវវិធានការ បង្ការទប់ស្កាត់និងបង្ក្រាបអំពើល្មើសច្បាប់ដែលពាក់ព័ន្ធដល់ការងារស្ថិតិ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការផ្តល់លិខិតឆ្លងដែនជូនប្រជាពលរដ្ឋ និងមុខរបរពិសេស ។

៤- សិក្សាស្រាវជ្រាវអំពីស្ថានភាព ភូមិសាស្ត្រ ស្ថានភាពប្រជាពលរដ្ឋ ដើម្បីពិចារណាដាក់ចេញនូវផែនការអំពីការកំណត់ទីតាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់និងការបំពាក់សំភារៈ

ឧបករណ៍មធ្យោបាយផ្សេងៗ អោយបានសមស្របទៅតាមសភាពការជាក់ស្តែងតាមតំបន់ភូមិសាស្ត្រ និងតាមដំណាក់កាលនីមួយៗ ដើម្បីធានាកិច្ចប្រតិបត្តិការឱ្យមានប្រសិទ្ធភាពខ្ពស់ ។

៥- តាមដានជាប្រចាំអំពីសភាពការណ៍និងការវិវត្តន៍ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់នៅទូទាំងប្រទេស តាមដំណាក់កាលនីមួយៗ ដើម្បីរាយការណ៍ និងលើកសំណូមពរជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីមានគោលការណ៍ វិធានការចំពោះមុខ និង យូរអង្វែង លើកិច្ចការអភិវឌ្ឍន៍ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ឱ្យរៀបរយជាបណ្តើរៗ សមស្របតាមសភាពការណ៍រីកចំរើនក្នុងតំបន់ និងសកលលោក ។

៦- ធ្វើរបាយការណ៍ជាប្រចាំ តាមការកំណត់ឬជាបន្ទាន់អំពីសភាពការណ៍ ហេតុការណ៍ផ្សេងៗ ដែលពាក់ព័ន្ធដល់ការអនុវត្តភារកិច្ចរបស់ខ្លួនជូនដល់អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ។

៧- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវវិន័យរបស់នគរបាលជាតិ កសាងស្នាដៃ និងកិត្តិយសរបស់នគរបាលជាតិ ។

៨- ធ្វើការងារបុគ្គលិក រដ្ឋបាល ភស្តុភារ គណនេយ្យរបស់នាយកដ្ឋានតាមការកំណត់របស់ក្រសួង ។

៩- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ប្រគល់អោយ ។

មាត្រា៩.-

នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គីភ័យមានសមត្ថកិច្ច និងភារកិច្ចដូចខាងក្រោម :

១- ផ្តើមយោបល់ លើកឡើងនូវគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីដាក់ចេញនូវផែនការ វិធានការណ៍សំដៅលើកកំពស់ប្រសិទ្ធភាពការងារគ្រប់គ្រងអាវុធជាតិផ្ទុះ និងការងារបង្ការ និងពន្លត់អគ្គីភ័យ ។

២- គ្រប់គ្រងការចុះបញ្ជី និងរៀបចំបែបបទផ្តល់លិខិតអនុញ្ញាតិប្រើប្រាស់អាវុធ តាមការកំណត់របស់រាជរដ្ឋាភិបាល ។

៣- ចុះតាមដានត្រួតពិនិត្យ និងណែនាំអំពីជំនាញគ្រប់គ្រងអាវុធ ជាតិផ្ទុះ នៅតាមស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ។

៤- ណែនាំ និងជំរុញដល់ការងារស្រាវជ្រាវ ដើម្បីរកឱ្យឃើញអាវុធជាតិផ្ទុះគ្រប់ប្រភេទដែលប្រើប្រាស់ ដឹកជញ្ជូន និងផ្ទេរ ទិញលក់ខុសច្បាប់ ។

៥- គ្រប់គ្រងការចុះបញ្ជីមូលដ្ឋានធ្វើអាជីវកម្ម និងមូលដ្ឋានផលិតកម្ម ដែលប្រើប្រាស់ជាតិផ្ទុះ ។

៦- គ្រប់គ្រង ដឹកនាំបញ្ជា ការងារបង្ការពន្លត់អគ្គីភ័យ និងសហការជាមួយកំលាំងសមត្ថកិច្ចផ្សេងៗទៀត ក្នុងការអង្កេត ស្រាវជ្រាវ និងធ្វើកោសល្យវិនិច្ឆ័យ នៃអគ្គីភ័យ ។

៧- ចុះហ្វឹកហ្វឺនដល់កំលាំងជំនាញឯកទេស ពន្លត់អគ្គីភ័យនៅតាមក្រសួងស្ថាប័ន គ្រឹះស្ថានសិក្សា រោងចក្រ សហគ្រាស និងកំលាំងពន្លត់អគ្គីភ័យរបស់ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ។

www.pheakdeylaw.com

៨- ឃោសនា ផ្សព្វផ្សាយអំពីវិធានការបង្ការទប់ស្កាត់ នៃគ្រោះមហន្តរាយ ដែលកើតឡើងដោយអគ្គីភ័យ ។

៩- គ្រប់គ្រងថែរក្សារថយន្ត និងឧបករណ៍ សំភារៈ សំរាប់បំរើឱ្យការងារពន្លត់អគ្គីភ័យ ។

១០- ធ្វើរបាយការណ៍ជាប្រចាំ តាមការកំណត់ឬជាបន្ទាន់អំពីសភាពការណ៍ ហេតុការណ៍ផ្សេងៗ ដែលពាក់ព័ន្ធដល់ការអនុវត្តភារកិច្ចរបស់ខ្លួនជូនដល់អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ។

១១- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវវិន័យរបស់នគរបាលជាតិ កសាងស្នាដៃ និង កិត្តិយសរបស់នគរបាលជាតិ ។

១២- ធ្វើការងារបុគ្គលិក រដ្ឋបាល ភស្តុភារ គណនេយ្យរបស់នាយកដ្ឋានតាមការកំណត់របស់ក្រសួង ។

១៣- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់អោយ ។

ជំពូកទី៥

អវសានប្បញ្ញត្តិ

មាត្រា៦.-

នាយកដ្ឋាននគរបាលរដ្ឋបាល និងនាយកដ្ឋានសន្តិសុខសង្គម ត្រូវបានរំសាយចោល ។

មាត្រា៧.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com